

(https://tools.freshnews.asia/banner/9krt0sz4b3.gif/click)

ណែត ស្នើសុំការយោគយល់ពីប្រជាពលរដ្ឋនៅរុនតាឯក ចំពោះការលំបាកកើតពីការរើសលំនៅឋាន។ សម្តេចធិបតី បានអះអាងថា នឹងបន្តប្រឹងប្រែ



(https://tools.freshnews.asia/banner/d4jl53h18a.gif/click)


ttps://tools.freshnews.asia/banner/evimnxom9g.gif/click)


(https://tools.freshnews


ttps://tools.freshnews.asia/banner/gonjhpse1p.gif/click)


(https://tools.freshnews


ttps://tools.freshnews.asia/banner/iwcu4skavh.gif/click)


(https://tools.freshnews

# ប្រសាសន៍សំខាន់ៗរបស់សម្តេចធិបតី ហ៊ុន ម៉ាណែត អញ្ជើញបើកសន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០២៣

2023-11-23 10:01am

**(ភ្នំពេញ)៖** នៅព្រឹកថ្ងៃព្រហស្បតិ៍ ១១កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៣នេះ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីកម្ពុជា អញ្ជើញសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០២៣ ដែលរៀបចំឡើងនៅសណ្ឋាគារសុខា។

**ខាងក្រោមជាខ្លឹមសារសំខាន់ៗរបស់សម្តេចធិបតី ហ៊ុន ម៉ាណែត៖**

* សម្តេចធិបតី ហ៊ុន ម៉ាណែត បានថ្លែងថា រាជរដ្ឋាភិបាល វាយតម្លៃខ្ពស់ចំពោះវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) ដែលបានសហការជាមួយស្ថាប័នជាតិ និងអន្តរជាតិ នានាជាច្រើន រៀបចំសន្និសីទដ៏មានសារៈសំខាន់នេះឡើង។

* សម្តេចធិបតី ហ៊ុន ម៉ាណែត សូមសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅ ចំពោះថ្នាក់ដឹកនាំនៃក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាល, វិស័យឯកជន, វិទ្យាស្ថានស្រាវជ្រាវ, អង្គការជាតិ និងអន្តរជាតិ និងដៃគូអភិវឌ្ឍន៍នានា ដែលបានអញ្ជើញចូលរួមដោយផ្ទាល់ក្នុងសន្និសីទនេះ។

* សម្តេចធិបតី ហ៊ុន ម៉ាណែត បានថ្លែងថា រាជរដ្ឋាភិបាលនីតិកាលទី៧ ចាត់ទុកសន្និសីទនេះជាវេទិកាដ៏សំខាន់ ដែលផ្តល់ឱកាសឱ្យតួអង្គពាក់ព័ន្ធទាំងអស់ ជាពិសេស «ស្ថាប័នស្រាវជ្រាវ» បានពិភាក្សា និងផ្លាស់ប្តូរយោបល់អំពីសមិទ្ធផល, បញ្ហាប្រឈម និង ទិសដៅយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍ ដោយផ្តោតសំខាន់លើការអនុវត្តជាក់ស្តែងផង និងភាពបត់បែនទៅ តាមការផ្លាស់ប្តូរនៃបរិការណ៍សកល និងតំបន់ផង ដើម្បីអាចនាំនាវាកម្ពុជាទៅកាន់វិបុលភាព ប្រកបដោយភាពធន់ និរន្តរភាព និងបរិយាប័ន្ន។

* សម្តេចធិបតី ហ៊ុន ម៉ាណែត បានថ្លែងថា រយៈពេលជាងពីរទស្សវត្សរ៍ចុងក្រោយនេះ ផ្តើមចេញពីនយោបាយឈ្នះ-ឈ្នះរបស់សម្តេចតេជោ ហ៊ុន សែន កម្ពុជាកសាងបាននូវមូលដ្ឋានគ្រឹះសេដ្ឋកិច្ចរឹងមាំសម្រាប់ការអភិវឌ្ឍន៍ ដោយប្រកាន់យកប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ ការបើកចំហរ ការធ្វើពាណិជ្ជកម្មអន្តរជាតិ ឈរលើគោលការណ៍ពហុភាគីនិយម។

* សម្តេចធិបតី ហ៊ុន ម៉ាណែត បានថ្លែងថា ការជំរុញ និងទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស ដើម្បីជាមូលដ្ឋានកសាងចន្ទល់សម្រាប់ទ្រទ្រង់កំណើនសេដ្ឋកិច្ច។

* សម្តេចធិបតី ហ៊ុន ម៉ាណែត បានថ្លែងថា ការពង្រឹង និងស្តារហេដ្ឋារចនាសម្ព័ន្ធរឹង ដូចជា ផ្លូវ ថ្នល់ ទឹក និងភ្លើង ដើម្បីលើកកម្ពស់ការតភ្ជាប់, សម្រួលការចល័តធនធាន និងកម្លាំងពលកម្ម ក៏ដូចជាពង្រាយមូលដ្ឋានផលិតកម្ម,

* សម្តេចធិបតី ហ៊ុន ម៉ាណែត បានថ្លែងថា ការបន្តអភិវឌ្ឍនិងលើកកម្ពស់មូលធនមនុស្ស ដើម្បីចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច និងបង្កើនផលិតភាព,

* សម្តេចធិបតី ហ៊ុន ម៉ាណែត បានថ្លែងថា ការកែទម្រង់ស្ថាប័ន និងអភិបាលកិច្ចជាប្រចាំ សម្រាប់ធានាប្រសិទ្ធភាពនៃការគ្រប់គ្រងប្រព័ន្ធនយោបាយ និងសេដ្ឋកិច្ច រួមទាំងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងប្រព័ន្ធធនាគារ ឱ្យមានប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ព្រមទាំងបែងចែកផ្លែផ្កាកំណើនឱ្យមានសមធម៌ និងបរិយាប័ន្ន ។

* សម្តេចធិបតី ហ៊ុន ម៉ាណែត បានថ្លែងថា ទោះបីកម្ពុជាបន្តរងនូវផលប៉ះទង្គិចវិបត្តិកូវីដ១៩ និងវិបត្តិផ្សេងៗទៀតក៏កំពុងបន្តកើតឡើង រាជរដ្ឋាភិបាលមិនបោះបង់ ឬផ្លាស់ប្តូរនូវទិសដៅអភិវឌ្ឍន៍រយៈពេលវែងនោះទេ រាជរដ្ឋាភិបាលនៅតែរក្សាគោលដៅសម្រេចមហិច្ឆតារបស់ខ្លួនដដែល គឺកម្ពុជាក្លាយជាប្រទេសចំណូលមធ្យមកំរិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។

* សម្តេចធិបតី ហ៊ុន ម៉ាណែត បានថ្លែងថា រាជរដ្ឋាភិបាលមិនឈប់ត្រឹមការដាក់ចេញនូវយុទ្ធសាស្ត្រប៉ុណ្ណោះទេ ប៉ុន្តែបានដាក់ចេញយន្តការកំណែទម្រង់ និងវិធានការជាក់ស្តែងជាបន្តបន្ទាប់ក្នុងរយៈពេលជាង ៣ខែកន្លងទៅនេះ, រាជរដ្ឋាភិបាលបានដាក់ ចេញជាបន្តបន្ទាប់នូវ «កម្មវិធីគោលនយោបាយអាទិភាព» ក្នុងនោះកម្មវិធីចំនួន៥ត្រូវបានប្រកាស និងដាក់ឲ្យចាប់ផ្តើមអនុវត្តរួចហើយ រួមមាន៖

(ទី១). «យុទ្ធសាស្ត្រជាតិ ស្តីពីការអភិវឌ្ឍសេដ្ឋកិច្ច ក្រៅប្រព័ន្ធ ឆ្នាំ ២០២៣-២០២៨», (ទី២). «ការពង្រីកវិសាល- ភាពមូលនិធិសមធម៌សុខាភិបាល ដល់គ្រួសារងាយរងហានិភ័យ» និង (ទី៣). «ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈនិងបច្ចេកទេសដល់យុវជនមកពីគ្រួសារក្រីក្រ និង ងាយរងហានិភ័យនៅទូទាំងប្រទេស» ជាមួយនឹងការពង្រីកវិសាលភាពរបបសន្តិសុខសង្គម ផ្នែកថែទាំសុខភាពដល់បុគ្គលស្វ័យនិយោ និងអ្នកក្នុងបន្ទុករបស់សមាជិក ប.ស.ស. ដោយផ្អែកលើគោលការណ៍អ្នកស្ម័គ្រចិត្ត (ទី៤). កម្មវិធីហិរញ្ញប្បទានលើកស្ទួយផលិតកម្មកសិកម្ម រកទីផ្សារ និងរក្សាលំនឹង ថ្លៃកសិកផលសំខាន់ៗក្នុងកំរិតសមរម្យ។ ទី៥). «ការដាក់ពង្រាយមន្ត្រីបច្ចេកទេសកសិកម្មទៅគ្រប់ឃុំ-សង្កាត់ ដែលមានសកម្មភាពកសិកម្មនៅទូទាំងប្រទេស និងការរៀបចំឲ្យមានសហគមកសិកម្មបែបថ្មី»។

* សម្តេចធិបតី ហ៊ុន ម៉ាណែត បានថ្លែងថា នៅក្នុងវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជនលើកទី ១៩, សម្តេចបានសម្រេចដាក់ចេញនូវវិធានការមុតស្រួច ដែលមានចរឹតជាការកែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាល អាណត្តិថ្មី ដើម្បីជំរុញដល់ការធ្វើពិពិធកម្មសេដ្ឋកិច្ច និងលើកកម្ពស់ភាពប្រកួតប្រជែងកម្ពុជា។






ttps://tools.freshnews.asia/banner/1b8df7gsya.gif/click)

* សម្តេចធិបតី ហ៊ុន ម៉ាណែត បានថ្លែងថា សម្តេចមានចំណាប់អារម្មណ៍ជាខ្លាំងលើកិច្ចពិភាក្សាទាំងបីវគ្គ ដែលសុទ្ធតែជាប្រធានបទមានសារៈសំខាន់ ជាពិសេសផ្នែកគោលនយោបាយ សម្រាប់កម្ពុជាអាចត្រៀមខ្លួនឱ្យបានល្អ និងគ្រប់គ្រាន់ ដើម្បីសម្រេចបង្គោលចរឆ្នាំ២០៣០ និងឆ្នាំបន្តបន្ទាប់ខាងមុខទៀត ។

* សម្តេចធិបតី ហ៊ុន ម៉ាណែត បានថ្លែងថា សេដ្ឋកិច្ចកម្ពុជាគឺជាសេដ្ឋកិច្ចបើកចំហរ ដូច្នេះការផ្លាស់ប្តូរជាវិជ្ជមាន និងអវិជ្ជមានពីកត្តាខាងក្រៅនឹងជះឥទ្ធិពលដោយផ្ទាល់ និងប្រយោលមក លើសក្តានុពលកំណើនកម្ពុជារយៈពេលមធ្យម-វែង។

* សម្តេចធិបតី ហ៊ុន ម៉ាណែត បានថ្លែងថា សម្តេចចង់ឃើញសន្និសីទរបស់យើងនាថ្ងៃនេះ គឺជាវេទិកានៃការផ្តោះប្តូរយោបល់ ត្រង់ទៅត្រង់មក ប្រកបដោយស្មារតីស្ថាបនា និងចូលរួមគិតគូរ អនុវត្ត និងទទួលខុសត្រូវរួមគ្នាលើ ជោគវាសនារបស់កម្ពុជា ។

* សម្តេចធិបតី ហ៊ុន ម៉ាណែត បានថ្លែងថា សម្តេចសង្ឃឹមជឿជាក់ថាសន្និសីទនាថ្ងៃនេះ នឹងប្រព្រឹត្តទៅដោយរលូន និងប្រកបដោយផ្លែផ្កា និងសូមប្រកាសបើក សន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ ២០២៣ ចាប់ពីពេលនេះតទៅ។

* សម្តេចធិបតី ហ៊ុន ម៉ាណែត បានបញ្ចប់ការថ្លែងសុន្ទរកថានៅវេលាម៉ោង៨៖៣៥នាទីនាព្រឹកថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៣។ សូមអរគុណចំពោះការទស្សនាផ្សាយផ្ទាល់តាមរយៈបណ្តាញទូរទស្សន៍ព័ត៌មាន Fresh News៕












(https://tools.freshnews


Cambodia Outlook Confe
"Cambodia Vision 2030 and
Charting A Path for Resilient, Sustainable, a
Phnom Penh, 23 November
Organized by
in partnership with
Australian Aid




ambodia Outlook Conference 2023
“Cambodia Vision 2030 and Beyond:
th for Resilient, Sustainable, and Inclusive Prosperity”
Phnom Penh, 23 November 2023
in partnership with


Cambodia Outlook Conference 2023
“Cambodia Vision 2030 and Beyond:
Phnom Penh, 23 November 2023
in partnership with
Australian Aid


Cambodia Outlook Conference 2023
“Cambodia Vision 2030 and Beyond:
Charting A Path for Resilient, Sustainable, and Inclusive Prosperity”
Phnom Penh, 23 November 2023
Organized by
in partnership with
Australian Aid
AMEICC


ambodia Outlook Conference 2023
“Cambodia Vision 2030 and Beyond:
th for Resilient, Sustainable, and Inclusive Prosperity”
Phnom Penh, 23 November 2023
in partnership with







រៀបចំដោយ























CAMBODIA
OUTLOOK
CONFERENCE




































(https://tools.freshnews.asia/banner/iqvyejt2nh.gif/click)



(https://tools.freshnews.asia/banner/q9gyytcwwy.gif/click)


(https://tools.freshnews.asia/banner/2yufcqlul6.gif/click)


## Sections

Home (https://www.freshnewsasia.com/index.php/en/?ref=1)
World News (http://www.freshnewsasia.com/index.php/en/international-news.html)
Analysis News (https://www.freshnewsasia.com/index.php/en/analysis.html)
Local News (https://www.freshnewsasia.com/index.php/en/localnews.html)
WATCH TV (http://www.freshnewsasia.com/watch/)
Traffic (https://www.freshnewsasia.com/index.php/en/102-live-traffic-cameras/3341-olympic.html)
Entertainment (https://www.freshnewsasia.com/index.php/en/entertainment.html)
English Version (http://en.freshnewsasia.com/)
Chinese (中文) (http://cn.freshnewsasia.com/)

## About Us

About (https://freshnewsasia.com/index.php/en/93-link-app/132443-2019-08-30-11-42-48.html)
Contact Us (https://freshnewsasia.com/index.php/en/93-link-app/132443-2019-08-30-11-42-48.html)


## Advertise with us

Tel: 017 608 006, Email: appfreshnews@gmail.com & Telegram


## Follow Our News

(https://www.facebook.com/freshnewsasia/)
(https://www.youtube.com/user/freshnewsvideo)
(https://t.me/freshnewsasia)




## Experience news with our Apps

(https://apps.apple.com/us/app/fresh-news/id854819078)
(https://play.google.com/store/apps/details?id=com.happysoft.freshnews&hl=en_US)


Copyright © 2021 FN Media Co.,Ltd.

E0E1-9D STREET 598 RUSSEY KEO PHNOM PENH
Phnom Penh, Phnom Penh 120705, Cambodia
Data Center By Fresh News